ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**សាលាដំបូងខេត្តកណ្តាល**
សំណុំរឿងរដ្ឋប្បវេណីលេខ ១៤៨
ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០
សាលក្រមលេខៈ **០១៥** (ឆ)
ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១

**តាងនាមប្រជារាស្ត្រខ្មែរ**
សាលាដំបូងខេត្តកណ្តាល
បានធ្វើការទាញហេតុផលដោយផ្ទាល់មាត់
ដោយមានសមាសភាព៖
លោក [redacted] ចៅក្រមសាលាដំបូងខេត្តកណ្តាល
លោក [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកណ្តាល

-សហដើមចោទ៖

១.ឈ្មោះ [redacted] **យ៉ុម** ភេទស្រី អាយុ ៦៨ឆ្នាំ មានអាសយដ្ឋាននៅភូមិ[redacted]។

២.ឈ្មោះ [redacted] **សុខលី** ភេទស្រី អាយុ ៥៧ឆ្នាំ មានអាសយដ្ឋាននៅភូមិ[redacted]។

អ្នកតំណាងដោយអាណត្តិឈ្មោះ [redacted] ជាមេធាវី អត្តលេខ ១០៣០។

-សហចុងចម្លើយ៖

១.ឈ្មោះ [redacted] **អេង** ភេទស្រី អាយុ ៥៩ឆ្នាំ មានអាសយដ្ឋាននៅភូមិ[redacted]។

២.ឈ្មោះ [redacted] **ចំរើន** ភេទប្រុស និងប្រពន្ធឈ្មោះ [redacted] **ចន្ទី** មានអាសយដ្ឋាននៅភូមិ[redacted]។

៣.ឈ្មោះ [redacted] **ហាក់** ភេទប្រុស និងប្រពន្ធឈ្មោះ [redacted] **ចន្ថា** មានអាសយដ្ឋាននៅភូមិ[redacted]។

អ្នកតំណាងដោយអាណត្តិឈ្មោះ [redacted] ជាមេធាវី អត្តលេខ **២០១២T** ។

## អង្គហេតុ និងចំណុចវិវាទ

### ១.ខ្លឹមសារសាលក្រមដែលប្តឹងទាមទារដោយដើមចោទ

១.សុំឲ្យសហចុងចម្លើយរុះរើសផ្ទះ របង និងគាស់ដំណាំផ្សេងៗ ចេញពីដីចំណីផ្លូវសាធារណៈរបស់រដ្ឋ ដែលបានធ្វើបិទក្បាលដីរបស់ឈ្មោះ [redacted] យ៉ុម និងឈ្មោះ [redacted] សុងលី មានទីតាំងស្ថិតនៅភូមិបឹងកណ្តាល ឃុំខ្ពបអាទាវ ស្រុកលើកដែក ខេត្តកណ្តាល។

២.បង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសងសំណងជម្ងឺចិត្ត សេវាកម្មមេធាវី និងបង់ពន្ធផ្សេងៗ នៅតុលាការ

សរុបចំនួន ២០,០០០,០០០៛ (ម្ភៃលាន) រៀល ។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយ ។

**២.ខ្លឹមសារសាលក្រមដែលប្ដឹងទាមទារដោយដើមបណ្ដឹងតប**

១.សុំទុកជាមោឃៈនូវពាក្យបណ្ដឹងរបស់ឈ្មោះ [redacted] យ៉ុម និងឈ្មោះ [redacted] សុងលី ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០ ចោលជាអសារបង់។

២.សុំតុលាការទុកជាត្រឹមត្រូវនូវៈ

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ F50077 ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩២ ចេញដោយប្រធានការិយាល័យភូមិបាលស្រុកលើកដែក ស្ថិតនៅភូមិបឹងកណ្ដាល ឃុំខ្ពបអាទាវ ស្រុកលើកដែក ខេត្តកណ្ដាល របស់ឈ្មោះ ប៉ក់ អេង ។

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ F50030 ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩២ ចេញដោយប្រធានការិយាល័យភូមិបាលស្រុកលើកដែក ខេត្តកណ្ដាល របស់ឈ្មោះ មឿន ចំរើន ។

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ F50041 ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩២ ចេញដោយប្រធានការិយាល័យភូមិបាលស្រុកលើកដែក ខេត្តកណ្ដាល របស់ឈ្មោះ សៀង ហាក់ ។

៣.ទាមទារសោហ៊ុយពេលវេលា សំណងជម្ងឺចិត្ត និងសេវាមេធាវីចំនួន ១០.០០០.០០០ (ដប់លាន) រៀល ។

៤.ពន្ធលើកម្មវត្ថុបណ្ដឹងតបជាបន្ទុករបស់ចុងបណ្ដឹងតប។

**៣.ការពន្យល់គ្រួសៗអំពីរឿងក្ដីៈ**

លោកមេធាវី [redacted] បានបញ្ជាក់ថាៈ កូនក្ដីខ្ញុំបាទមានដីម្នាក់មួយប្លង់មានព្រំប្រទល់ជាប់គ្នាដោយដីរបស់ឈ្មោះ [redacted] យ៉ុម មានទទឹង១៦ម៉ែត្រ និងបណ្ដោយ៥២ម៉ែត្រ ចំណែកដីរបស់ឈ្មោះ [redacted] **សុងលី** មានទទឹង ៣៥ម៉ែត្រ និង បណ្ដោយ៥២ម៉ែត្រ មានព្រំប្រទល់ខាងកើតទល់នឹងដីចំណីផ្លូវជាតិលេខ ១៤ មានទីតាំងស្ថិតនៅភូមិបឹងកណ្ដាលឃុំខ្ពបអាទាវ ស្រុកលើកដែក ខេត្តកណ្ដាល។ នៅឆ្នាំ ២០១៨ ផ្លូវចាក់កៅស៊ូ១ខ្សែ នៅតាមបណ្ដោយមាត់ទន្លេមេគង្គក្រោម ស្ថិតនៅក្នុងភូមិសាស្ត្រភូមិបឹងកណ្ដាល ឃុំខ្ពបអាទាវ ស្រុកលើកដែក ខេត្តកណ្ដាល រងការខូចខាតដោយសារការបាក់ច្រាំងទន្លេមិនអាចឱ្យប្រជាពលរដ្ឋធ្វើដំណើរបាន ទើបនៅ ដើមឆ្នាំ ២០១៨ ក្រសួងសាធារណៈការ និងដឹកជញ្ជូន បានស្ថាបនាផ្លូវថ្មី មួយខ្សែ នៅខាងក្រោយផ្លូវចាស់ (១៤) ដោយសារផ្លូវចាស់រងការខូចខាតនេះហើយផ្លូវថ្មីនេះកាត់ចំកន្ទុយដីរបស់ឈ្មោះ [redacted] **អេង** និងឈ្មោះ [redacted] **ហាក់** ប្រពន្ធឈ្មោះ [redacted] **ចន្ថា** ហើយក៏កាត់ចំពីមុខក្បាលដីរបស់កូនក្ដីខ្ញុំបាទទាំងពីរនាក់ ។ មុនស្ថាបនាផ្លូវនេះរដ្ឋបានដោះស្រាយផលប៉ះពាល់ឱ្យទៅឈ្មោះ [redacted] **អេង** និងឈ្មោះ [redacted] **ហាក់** ប្រពន្ធឈ្មោះ [redacted] **ចន្ថា** រួចរាល់អស់ហើយដោយរដ្ឋទិញយកក្នុង១ម៉ែត្រការ៉េ តម្លៃ៨,៥$ (ប្រាំបីដុល្លារប្រាំកាក់)។

នៅពេលក្រសួងសាធារណៈការ និងដឹកជញ្ជូនស្ថាបនាផ្លូវនេះមិនទាន់រួចផង នៅដើមខែកុម្ភៈ ឆ្នាំ ២០២០ ឈ្មោះ [redacted] អេង បានធ្វើរបងរៀបឥដ្ឋកម្ពស់ប្រហែល ១ម៉ែត្រនិងឱ្យក្មួយឈ្មោះ [redacted] ចំរើន និងប្រ ពន្ធឈ្មោះ [redacted] ចន្ទី ធ្វើផ្ទះរំលោភលើដីចំណីផ្លូវសាធារណៈរដ្ឋ ដែលរដ្ឋបានដោះស្រាយផលប៉ះពាល់រួច

ហើយ ហើយបិទផ្លូវកូនក្តីរបស់ខ្ញុំបាទដែលមានក្បាលដីជាប់និងផ្លូវថ្មីនេះមិនឱ្យចេញចូលបាន។ ការសាងសង់របស់ឈ្មោះ [redacted] ចំរើន និងប្រពន្ធឈ្មោះ [redacted] ចន្ទី រំលោភនឹងសេចក្តីជូនដំណឹងលេខ:១០៥០ សក.កណ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ និងសេចក្តីជូនដំណឹងលេខ:១០៦៧ សក.កណ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ របស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកណ្តាល ហើយសំណង់នេះគ្មានច្បាប់អនុញ្ញាត។ ពេលឃើញឈ្មោះ [redacted] ចំរើន និងប្រពន្ធឈ្មោះ [redacted] ចន្ទី ធ្វើផ្ទះលើដីចំណីផ្លូវបិទផ្លូវមិនឱ្យឈ្មោះ [redacted] សុងលី ចេញចូល ឈ្មោះ [redacted] ហាក់ និងប្រពន្ធឈ្មោះ [redacted] ចិន្តា ក៏បានយកចេក ល្ហុង ស្លឹកគ្រៃ មកដាំលើដីចំណីផ្លូវជាតិផងដែរ ព្រមទាំងយកឫស្សីរាំងបិទផ្លូវក្បាលដីឈ្មោះ [redacted] យ៉ុម មិនឱ្យចេញចូលបានដែរ។ ដោយសហដើមចោទមិនមានផ្លូវចេញចូលទីកាន់ដីចំការរបស់ខ្លួន ពេលកូនក្តីខ្ញុំបាទបានប្តឹងចូលទៅលោកមេឃុំខ្ពបអាទាវឱ្យជួយដោះស្រាយសម្របសម្រួល ហើយអាជ្ញាធរឃុំបានកោះហៅមកដោះស្រាយចំនួន ៣ លើក ប៉ុន្តែភាគីឈ្មោះ [redacted] អេង មិនព្រមរុះរើសរបងចេញពីដីចំណីផ្លូវទេ ថែមទាំងឱ្យក្មួយរបស់គាត់ឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] ចន្ទី ធ្វើផ្ទះលើដីចំណីផ្លូវបិទផ្លូវមិនឱ្យកូនក្តីខ្ញុំបាទចេញចូលបាន។ ហើយលោកមេឃុំបានបញ្ជូនសំណុំរឿងនេះទៅកាន់សាលាស្រុកទៀត ហើយអាជ្ញាធរបានកោះហៅភាគីឈ្មោះ [redacted] អេង ចំនួន ៣ លើកទៀតមកដោះស្រាយ ប៉ុន្តែភាគីឈ្មោះ [redacted] អេង នៅតែមិនព្រមរុះរើសរបងនិងផ្ទះចេញពីដីចំណីផ្លូវឱ្យកូនក្តីខ្ញុំបាទចេញចូលទេ ទើបកូនក្តីខ្ញុំទាំងពីរនាក់សម្រេចចិត្តដាក់ពាក្យប្តឹងចូលមកសាលាដំបូងខេត្តកណ្តាលឱ្យជួយដោះស្រាយរកយុត្តិធម៌។

**៤.ការអះអាងរបស់ភាគី**

-មេធាវីឈ្មោះ [redacted] ជាអ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទបានអះអាងថា: ឈ្មោះ [redacted] អេង ឈ្មោះ [redacted] ចន្ទី ឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] ហាក់ ប្រពន្ធឈ្មោះ [redacted] ចន្ថា បានធ្វើរបង និងផ្ទះរំលោភលើដីចំណីផ្លូវសាធារណៈ ព្រមទាំងបានបិទផ្លូវកូនក្តីខ្ញុំបាទដែលមានក្បាលដីជាប់និងផ្លូវថ្មីនេះមិនឱ្យចេញចូលបាន។ ហើយសហចុងចម្លើយមិនមានដីនៅសល់ផ្នែកខាងលិចផ្លូវជាតិលេខ ១៤ នេះទៀតទេ។ អំពើរបស់សហចុងចម្លើយខាងលើនេះ បានរំលោភលើសេចក្តីជូនដំណឹងលេខ: ១០៥០ សក.កណ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ និងសេចក្តីជូនដំណឹងលេខ: ១០៦៧ សក.កណ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨ របស់មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្តកណ្តាល។ ដោយរដ្ឋក៏បានដោះស្រាយសំណងប៉ះពាល់លើដីរបស់ឈ្មោះ [redacted] អេង និងឈ្មោះ [redacted] ហាក់ ព្រមនិងប្រពន្ធឈ្មោះ [redacted] ចន្ថា រួចរាល់អស់ហើយដែរ។ដូច្នេះដីនេះត្រូវបានផ្លាស់ប្តូរស្ថានភាពពីដីកម្មសិទ្ធិឯកជនមកជាដីសាធារណៈរបស់រដ្ឋ(ដីចំណីផ្លូវសាធារណៈរបស់រដ្ឋ) លែងជាកម្មសិទ្ធិឯកជនរបស់ឈ្មោះ [redacted] អេង និងឈ្មោះ [redacted] ហាក់ និង ប្រពន្ធឈ្មោះ [redacted] ចន្ថា ទៀតហើយ។

-មេធាវីឈ្មោះ [redacted] ជាអ្នកតំណាងដោយអាណត្តិរបស់សហចុងចម្លើយបានថ្លែងការណ៍ថា: ខ្លួនច្រាលចោលការទាមទាររបស់អ្នកតំណាងរបស់សហដើមចោទគ្រប់ចំណុចទាំងអស់ និងសូមឱ្យតុលាការទុក ជាត្រឹមត្រូវនូវ:

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ F50077 ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩២ ចេ ញដោយប្រធានការិយាល័យភូមិបាលស្រុកលើកដែក ស្ថិតនៅភូមិបឹងកណ្តាល ឃុំខ្ពបអាទាវ ស្រុក



Scanned with CamScanner

លើកដែក ខេត្តកណ្ដាល របស់ឈ្មោះ [redacted] អេង ។

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ F50030 ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩២ ចេញដោយប្រធានការិយាល័យភូមិបាលស្រុកលើកដែក ខេត្តកណ្ដាល របស់ឈ្មោះ [redacted] ចំរើន ។

-ប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ F50041 ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩២ ចេញដោយប្រធានការិយាល័យភូមិបាលស្រុកលើកដែក ខេត្តកណ្ដាល របស់ឈ្មោះ សៀង ហាក់ ។

ចំពោះពាក្យបណ្ដឹងរបស់សហដើមចោទដែលបានប្ដឹងកូនក្ដីរបស់ខ្ញុំបាទគឺគ្មានមូលហេតុត្រឹមត្រូវ ដោយខ្ញុំបាទសូមធ្វើការបញ្ជាក់បន្ថែមដូចខាងក្រោម៖

-ប្រវត្តិដីរបស់ឈ្មោះ [redacted] សុងលី ម្ចាស់ដីដើមនៃដីនេះគឺឈ្មោះ [redacted] មន ដែលជាអ្នកមានសិទ្ធិកាន់កាប់ហើយឈ្មោះ [redacted] មន បានបំបែកក្បាលដីនេះ ជា ពីរ ក្បាលដីគឺមួយបានលក់ឱ្យទៅឈ្មោះ [redacted] សឿន ដែលក្បាលដីជាប់ផ្លូវទំនាប់ទឹក ដែលអាចធ្វើដំណើរទៅផ្លូវជាតិលេខ ១៤ ចាស់បាន និងទីពីរចែកឱ្យកូនរបស់គាត់ឈ្មោះ [redacted] ជី ជាអ្នកកាន់កាប់នៃដីនេះ មិនមានផ្លូវចេញចូលទេ តែឆ្លងកាត់តាមដីរបស់ឈ្មោះ [redacted] សឿន បានដោយសារដីនេះបានបំបែកជាពីរក្បាលដីគឺក្លាយជាដីបិទជិត។ ទើបដីរបស់ឈ្មោះ [redacted] ជី ចេញចូលឆ្លងកាត់ដីរបស់ឈ្មោះ [redacted] សឿន រហូតបន្ទាប់មកឈ្មោះ [redacted] ជី បានលក់ដីរបស់ខ្លួនឱ្យមកឈ្មោះ [redacted] សុងលី បន្តរហូតមកដល់សព្វថ្ងៃនេះ។

កាលនៅប្រើប្រាស់ផ្លូវជាតិលេខ ១៤ ចាស់ ដីរបស់ឈ្មោះ [redacted] សុងលី ជាប់និងកន្ទុយដីរបស់ឈ្មោះ [redacted] អេង និងឈ្មោះ [redacted] ចំរើន ហើយផ្លូវចេញចូលទៅដីរបស់ [redacted] សុងលី គឺឆ្លងកាត់ចេញចូលតាមដីរបស់ឈ្មោះ [redacted] សឿន ជាដីជាប់របងជាមួយគ្នា។

ដីរបស់ឈ្មោះ [redacted] សុងលី ដែលបានឆ្លងកាត់ដីរបស់ឈ្មោះ [redacted] សឿន ដើរទៅកាន់ផ្លូវទំនប់ទឹក ឆ្ពោះទៅរកផ្លូវជាតិលេខ ១៤ ចាស់ បានដោយមិនមានពាក់ព័ន្ធនិងដីរបស់ឈ្មោះ [redacted] អេង និងឈ្មោះ [redacted] ចំរើន ឡើយ។

ក្នុងអំឡុងឆ្នាំ២០១៨ ផ្លូវជាតិលេខ ១៤ ចាស់បានបាក់ចូលក្នុងទន្លេមេគង្គក្រោមធ្វើឱ្យខូចខាតទាំងស្រុង ទើកក្រសួងសាធារណៈការណ៍ និងដឹកជញ្ជូន បានស្ថាបនាផ្លូវជាតិលេខ ១៤ ថ្មីឡើងវិញដែលផ្លូវជាតិលេខ ១៤ ថ្មីនេះត្រូវឆ្លងកាត់មកលើដីរបស់ឈ្មោះ [redacted] អេង និងឈ្មោះ [redacted] ចំរើន ទើបធ្វើឱ្យដីរបស់កូនក្ដីខ្ញុំបាទនៅសល់ដីទាំងសងខាងផ្លូវជាតិលេខ ១៤ ថ្មីនេះ។ ដោយសារដីរបស់កូនក្ដីខ្ញុំនៅសល់ខាងកើតផ្លូវជាតិលេខ ១៤ថ្មី ដែលជាប់ផ្លូវចាស់ ងាយរងនិងការបាក់ច្រាំងចូលក្នុងទន្លេមេគង្គ មិនអាចសាងសង់លំនៅដ្ឋានបានឡើយ។

-ចំពោះប្រវត្តិដីរបស់ឈ្មោះ [redacted] យ៉ុម ជាដីដែលបានអំណោយពីឈ្មោះ [redacted] ហាក់ ដែលត្រូវជាបងប្អូននឹងគ្នាដោយឈ្មោះ [redacted] ហាក់ បានប្រគល់ដីដែលមានទំហំទទឹងចំនួន ១៦ម៉ែត្រ និងបណ្ដោយចំនួន ៥០ម៉ែត្រ ជាអំណោយឱ្យទៅឈ្មោះ [redacted] យ៉ុម ក្នុងអំឡុងឆ្នាំ ១៩៨១ ឬ១៩៨២។ ដោយឈ្មោះ [redacted] ហាក់ គិតថាឈ្មោះ [redacted] យ៉ុម ជាប្អូនអត់មានដីដាំដំណាំ ទើបចែកកន្ទុយដីនេះឱ្យដើម្បីដាំដំណាំផ្សេងៗរហូតដល់ពេលបច្ចុប្បន្ននេះ។ សូមអះអាងអង្គហេតុខាងលើនេះ ពិតជាត្រឹមត្រូវ ដោយមានភស្តុតាងយកមកបញ្ជាក់ និងភ្ជាប់ជូនមកតុលាការដើម្បីពិនិត្យនិងពិចារណាក្នុងការ សម្រេចសេចក្ដី



Scanned with CamScanner

ដោយយុត្តិធម៌។ ដែលសំអាងហេតុរបស់ សហដើមចោទថា យើងខ្ញុំយកដីចំណីផ្លូវសាធារណៈរបស់រដ្ឋមកជាសិទ្ធិកាន់កាប់របស់ខ្លួននោះ ជាការចោទប្រកាន់ដោយគ្មានភស្តុតាង និងជាការលោភសិទ្ធិកាន់កាប់ដោយស្របច្បាប់របស់កូនក្តីខ្ញុំបាទ។ ចំណែកទាក់ទងនឹងដីបិទជិតនេះ ដោយយោងតាមប្រវត្តិដីរបស់ ឈ្មោះ [redacted] សុងលី និងឈ្មោះ [redacted] យ៉ុម គឺមិនធ្លាប់បានឆ្លងកាត់មកលើដីរបស់កូនក្តីខ្ញុំឡើយ និងសូមធ្វើការបញ្ជាក់បន្ថែមផងដែរថាដីបិទជិតរបស់ឈ្មោះ [redacted] សុងលី និងឈ្មោះ [redacted] យ៉ុម ដែលនៅពីក្រោយដីកូនក្តីខ្ញុំបាទ គឺជាប្រភេទដីកសិកម្ម។

-លោកមេធាវីឈ្មោះ [redacted] បានអះអាងថាសម្រាប់ការសុំបើកផ្លូវរបស់សហដើមចោទ កូនក្តីរបស់ខ្ញុំបាទយល់ព្រមធ្វើការបើកផ្លូវដើម្បីឱ្យសហដើមចោទចេញចូលពីដី ទៅកាន់ផ្លូវជាតិលេខ ១៤ ថ្មី ដែលទទឹងទំហំ ៤ ម៉ែត្រ និងបណ្តោយពីព្រំដីរបស់សហដើមចោទទៅផ្លូវជាតិលេខ ១៤ ថ្មី ដែលទីតាំងសម្រាប់ការបើកផ្លូវនេះស្ថិតនៅត្រង់ចំណុចនៃព្រំដីជាប់គ្នារវាងសហដើមចោទ រហូតមកដល់ផ្លូវជាតិលេខ ១៤ ថ្មី។ ចំពោះទទឹង ៤ ម៉ែត្រនៃដីបើកនេះត្រូវបែងចែកជាពីរ គឺចំនួន ២ ម៉ែត្រ ជារបស់សហដើមចោទឈ្មោះ [redacted] សុងលី និងចំនួន ២ ម៉ែត្រទៀត ជារបស់សហដើមចោទឈ្មោះ [redacted] យ៉ុម ហើយស្ថិតនៅជាប់គ្នាតែម្តង ដោយកំណត់ទីតាំងសម្រាប់បើកផ្លូវចេញចូល នៅត្រង់ចំណុចក្បាលដីដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ F50077 ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩២ ចេញដោយប្រធានការិយាល័យភូមិបាលស្រុកលើកដែក ស្ថិតនៅភូមិបឹងកណ្តាល ឃុំខ្ពបអាទាវ ស្រុកលើកដែក ខេត្តកណ្តាល របស់ឈ្មោះ [redacted] អេង ។

-របាយការណ៍ស្តីពីករណីទំនាស់ដីធ្លីរវាងឈ្មោះ [redacted] សុងលី ឈ្មោះ [redacted] យ៉ុម និងឈ្មោះ [redacted] អេង ឈ្មោះ [redacted] ចន្ថា របស់លោក [redacted] ច័ន្ទវិទ្យា ជាអភិបាលស្រុកលើកដែក បានបញ្ជាក់ថាៈ ប្រធាន និង អនុប្រធាន ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាល បានចុះធ្វើការវាស់វែងលើចំណុចនៃដីទំនាស់ជាលទ្ធផល យល់ឃើញថា ដីឈ្មោះ [redacted] ប៉ក់ កូនឈ្មោះ [redacted] អេង និងឈ្មោះ សៀង ហាក់ ដែលរដ្ឋសងផលប៉ះពាល់ដើម្បីធ្វើផ្លូវជាតិវាងថ្មី (លេខ ១៤) ដោយមូលហេតុបាក់ច្រាំងទន្លេមេគង្គ គឺជាដីដែលបានកាន់កាប់ដីអង្គភាពភូមិ ស្ថិតនៅក្រៅប្លង់ដែលចេញឱ្យប្រើប្រាស់ជាផ្លូវការក្នុងឆ្នាំ១៩៩២ ។

**ចំណុចវិវាទៈ**

-ដីចំណីផ្លូវរបស់រដ្ឋ ។

-ការបើកផ្លូវចេញចូលទៅកាន់ដីរបស់សហដើមចោទ ដែលត្រូវឆ្លងកាត់ដីរបស់សហចុងចម្លើយ ឈ្មោះ [redacted] អេង ឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] ហាក់ ។

## សំអាងហេតុ

១.តាមពាក្យបណ្តឹងសុំបើកផ្លូវ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០របស់សហដើមចោទឈ្មោះ [redacted] សុងលី និងឈ្មោះ [redacted] យ៉ុន និងពាក្យសុំបណ្តឹងសុំកែតម្រូវកម្មវត្ថុបណ្តឹង ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២០ របស់អ្នកតំណាងដោយអាណត្តិឱ្យសហដើមចោទ ។ តុលាការគប្បីលើកមកពិចារណា ។

២.តាមពាក្យបណ្តឹងតប ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ របស់អ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយ ។ តុលាការគប្បីលើកមកពិចារណា។

៣.តាមការអះអាងរបស់ភាគីអាចបញ្ជាក់ឱ្យឃើញថា ដីរបស់ឈ្មោះ [redacted] សុងលី និងដីរបស់ឈ្មោះ [redacted] យ៉ុម គឺជាដីបិទជិតដែលគ្មានផ្លូវចេញចូលទៅកាន់ផ្លូវសាធារណៈក្នុងការឆ្លងកាត់បានឡើយ ក្រោយពីរដ្ឋធ្វើបានធ្វើការស្ថាបនាផ្លូវវាងថ្មី (លេខ ១៤) ដែលស្ថាបនាដើម្បីជំនួសឱ្យប្រើប្រាស់ផ្លូវជាតិលេខ ១៤ ចាស់ដែលបានទទួលរងការខូចខាតដោយការបាក់ចូលច្រាំងទន្លេមេគង្គ។

៤.តាមការអះអាងរបស់លោកមេធាវីតំណាងដោយអាណត្តិឱ្យសហចុងចម្លើយបញ្ជាក់ឱ្យឃើញថា ភាគីសហចុងចម្លើយយល់ព្រមក្នុងការបើកផ្លូវ ដើម្បីឱ្យសហដើមចោទធ្វើការចេញចូលទៅកាន់ដីរបស់ខ្លួនបានដោយទទឹងទំហំ ៤ ម៉ែត្រ និងបណ្តោយពីព្រំដីជាប់គ្នារវាងសហដើមចោទៅថ្នល់ជាតិលេខ ១៤ ថ្មី ដោយកំណត់ពីទំហំទទឹង ៤ម៉ែត្រ គិតពីព្រំដីជាប់គ្នាទៅកាន់ក្បាលដីទាំងពីររបស់សហដើមចោទទំហំ ២ ម៉ែត្រ ដោយកំណត់ទីតាំងត្រង់ចំណុចក្បាលដីដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ F50077 ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ១៩៩២ ចេញដោយប្រធានការិយាល័យភូមិបាលស្រុកលើកដែក ដែលមានសហចុងចម្លើយឈ្មោះ [redacted] អេង ជាអ្នកមានសិទ្ធិកាន់កាប់ ។

៥.ដើម្បីជាប្រយោជន៍ក្នុងការធ្វើដំណើរចេញទៅផ្លូវសាធារណៈ សហដើមចោទបាន ដាក់ពាក្យសុំបើកផ្លូវមកតុលាការដើម្បីបើកផ្លូវសម្រាប់ដីបិទជិតស្របតាមមាត្រា ១៤៤ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា។

៦.យោងតាមរបាយការណ៍ស្តីពីករណីទំនាស់ដីធ្លីរវាងឈ្មោះ សៅ សុងលី ឈ្មោះ ឆេង យ៉ុម និងឈ្មោះ ប៉ក់ អេង ឈ្មោះ យ៉ែម ចន្ថា របស់លោកអភិបាលស្រុកលើកដែកឈ្មោះ [redacted] **ច័ន្ទវិទ្យា** បានធ្វើការបញ្ជាក់ពីលទ្ធផលនៃការវាស់វែងជាក់ស្តែង និងតាមការវាស់វែងជាក់ស្តែង និងការពិនិត្យទៅនឹងគំនូសទីតាំងដី ក្នុងគោលបញ្ជីតម្កល់នៅការិយាល័យរៀបចំដែនដី នគរូបនីយកម្មសំណង់ និងភូមិបាលស្រុកលើកដែក មានភាពត្រឹមត្រូវ តុលាការសម្រេចយកជាមូលដ្ឋានសម្រាប់ការធ្វើការពិចារណា ។

៧.យោងតាមសំអាងហេតុចំណុចទី៣, ទី៤ និង ទី៥ គប្បីឱ្យតុលាការធ្វើការពិចារណាទៅលើអង្គហេតុនិងអង្គច្បាប់នៅក្នុងរឿងក្តីនេះ ដើម្បីជៀសវាងនូវការខូចខាតផលប្រយោជន៍ស្របច្បាប់របស់សហចុងចម្លើយឈ្មោះ [redacted] អេង ។ តុលាការគប្បីវិនិច្ឆ័យសេចក្តីដោយផ្អែកទៅលើតថភាពនៃភស្តុតាងជាក់ស្តែងនៃសំណុំរឿង។

៨.ចំពោះការសុំបើកផ្លូវតាមរយៈទំនាក់ទំនងនៃដីបិទជិតនេះតម្រូវឱ្យសហដើមចោទទទួលបន្ទុកលើការបង់ប្រាក់សំណង តាមការខូចខាតដោយការឆ្លងកាត់ដីដែលបានបើកនោះឱ្យទៅសហចុងចម្លើយដោយផ្អែកតាមមាត្រា ១៤៤ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី ឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា។

៩.ចំពោះសំណងជម្ងឺចិត្តរបស់សហដើមចោទ តាមរយៈពាក្យសុំបើកផ្លូវ និងពាក្យសុំកែតម្រូវកម្មវត្ថុនៃពាក្យសុំបើកផ្លូវ និងសំណងជម្ងឺចិត្តរបស់សហចុងចម្លើយតាមរយៈពាក្យបណ្តឹងតប ដែលដាក់មកកាន់តុលាការ។ តុលាការគប្បីធ្វើការលើយកមកវិនិច្ឆ័យសេចក្តី និងសម្រេចសេចក្តីតាមច្បាប់។

១០.ចំពោះប្រាក់ប្រដាប់ក្តី តុលាការគប្បីសម្រេចពិចារណាកំណត់នូវអ្នកទទួលបន្ទុកប្រាក់ប្រដាប់ក្តីដោយផ្អែកតាមមាត្រា ៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

## សាលាដំបូងខេត្តកណ្ដាល
## វិនិច្ឆ័យសម្រេច

១-ទទួលពាក្យបណ្ដឹង ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ របស់សហដើមចោទឈ្មោះ [redacted] យ៉ុម និង ឈ្មោះ [redacted] សុងលី ទុកជាបានការ ត្រឹមត្រូវតាមច្បាប់។

២-ទទួលពាក្យបណ្ដឹងតប ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២០ របស់អ្នកតំណាងដោយអាណត្តិឱ្យសហចុងចម្លើយឈ្មោះ [redacted] អេង ឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] ហាក់ ទុកជាបានការត្រឹមត្រូវតាមច្បាប់។

៣-បង្គាប់ឱ្យសហចុងចម្លើយឈ្មោះ [redacted] អេង ឈ្មោះ [redacted] ចំរើន និងឈ្មោះ [redacted] ហាក់ បើកផ្លូវទទឹង ៤ ម៉ែត្រ និងបណ្ដោយពីព្រំដីរបស់សហដើមចោទឈ្មោះ [redacted] យ៉ុម និងឈ្មោះ [redacted] សុងលី ទៅថ្នល់ជាតិលេខ ១៨ ថ្មី នៅត្រង់ចំណុចព្រំដីជាប់គ្នារវាងសហដើមចោទ ស្ថិតនៅភូមិបឹងកណ្ដាល ឃុំខ្ពបអាទាវ ស្រុកលើកដែក ខេត្តកណ្ដាល ត្រង់ចំណុចក្បាលដីដែលមានប័ណ្ណសម្គាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ F50077 ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ១៩៩២ចេញដោយប្រធានការិយាល័យភូមិបាលស្រុកលើកដែក ស្ថិតនៅភូមិបឹងកណ្ដាល ឃុំខ្ពបអាទាវ ស្រុកលើកដែក ខេត្តកណ្ដាល របស់សហចុងចម្លើយឈ្មោះ [redacted] អេង ។

៤-បង្គាប់ឱ្យសហដើមចោទឈ្មោះ [redacted] សុងលី និងឈ្មោះ [redacted] យ៉ុម ទទួលបន្ទុកសងសំណងនៃការខូចខាតដោយការឆ្លងកាត់ដីដែលបានបើកផ្លូវ ទទឹងប្រវែង ៤ ម៉ែត្រ និងបណ្ដោយប្រវែងពីព្រំដីជាប់គ្នារបស់សហដើមចោទទៅថ្នល់ជាតិលេខ ១៨ ថ្មី តាមតម្លៃជាក់ស្ដែង ទៅឱ្យសហចុងចម្លើយឈ្មោះ [redacted] អេង។

៥-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ សហដើមចោទ។

ទុកសិទ្ធិឲ្យធ្វើការប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

**ចៅក្រម**

ក្រឡាបញ្ជី [redacted]    ហត្ថលេខា និង ត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម ។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ខេត្តកណ្ដាល ថ្ងៃទី ២៨ ខែ មករា ឆ្នាំ២០២១

បានឃើញ

**ចៅក្រម**

[redacted]

**ក្រឡាបញ្ជី**

[redacted]